# សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ូ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធមណ្ឌលសុខភាពឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប
# ថ្ងៃទី១៣ ខែមិនា ឆ្នាំ ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព ឯកឧត្តម តែ គុយស៊ាង លេខាធិការក្រសួងសុខាភិបាល
- សូមគោរព ឯកឧត្តម សាង វីហា អភិបាលរងខេត្ត
- សូមគោរព លោកវេជ្ជបណ្ឌិត គ្រួស សារ៉ាត់ ប្រធានមន្ទីរសុខាភិបាលខេត្តសៀមរាប
- សូមគោរព លោក អ៊ែនទ្រូ ហៀល អនុប្រធានអង្គការភ្លែនអន្តរជាតិ-កម្ពុជា
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីសម្ពោធគម្រោងសម្រាប់ការសាងសង់ណ្ឌលសុខភាពឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម តែ គុយស៊ាង លេខាធិការក្រសួងសុខាភិបាល។ ជាបឋម ខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តម តែ គុយស៊ាង លេខាធិការក្រសួងសុខាភិបាល និងបុគ្គលិកអង្គការភ្លែនអន្តរជាតិ-កម្ពុជា ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់ដែលបានចូលរួមក្នុងពិធីនេះ។

ការពង្រឹងផ្នែកសុខាភិបាល គឺជាការកំណែទម្រង់មួយដ៏សំខាន់នៃបណ្តាកំណែទម្រង់ដទៃទៀត ដែលបានធ្វើអោយមានការរីកចម្រើនជាលំដាប់ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីរបស់រាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋាភិបាលជប៉ុនបាននឹងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការពង្រឹងផ្នែកសុខាភិបាល តាមរយៈការអភិវឌ្ឍធនធានមនុស្ស និងការកែលម្អស្ថានភាពមណ្ឌលសុខភាពថែទាំវេជ្ជសាស្ត្ររួមមាន ការសាងសង់មជ្ឈមណ្ឌលមាតាជាតិនិងកុមារ តាមរយៈការជំនួយឧត្តម្គតសំណង។

គម្រោងនេះ គឺដើម្បីសាងសង់មណ្ឌលសុខភាព ព្រមទាំងបំពាក់សម្ភារៈសុខាភិបាលរួមមាន មីក្រូទស្សន៍មួយ និងគ្រែអ្នកជម្ងឺចំនួន៩ ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។ គម្រោងនេះ មានគោលបំណងអោយប្រជាជនក្នុងតំបន់ប្រមាណ ៦,៤០០នាក់ ដែលមានទីតាំងចំងាយ១០គីឡូម៉ែត្រពីមណ្ឌលសុខភាពដែលនៅជិតបំផុត ទទួលបានការព្យាបាលអោយកាន់តែមានសុវត្ថិភាព និងមានការយកចិត្តទុកដាក់ខ្ពស់ ហើយគម្រោងនេះត្រូវបានរំពឹងថា នឹងចូលរួមចំណែកជួយសម្រាលស្ថានភាពសុខភាពនៅក្នុងតំបន់។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មណ្ឌលសុខភាពឃុនរាមនេះ នឹងពង្រីកការផ្តល់សេវាសុខាភិបាលក្នុងខេត្តសៀមរាបបន្តទៅទៀត ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើននឹងបានទទួលអត្ថប្រយោជន៍ពីសេវាសុខាភិបាលកាន់តែល្អប្រសើរ ដែលផ្តល់ដោយមន្ទីរពេទ្យ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមដោយស្មោះសរថាមណ្ឌលសុខភាពនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវនិងប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជន ជប៉ុននិងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។**